# WE’RE HIRING

អេ អឹម ខេ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលឈានមុខគេមួយក្នុងប្រទេសកម្ពុជា ដែលមានបណ្តាញប្រតិបត្តិការទូទាំង ប្រទេស។ បច្ចុប្បន្ននេះ អេ អឹម ខេ មានបុគ្គលិកជាង ៣,៧០០ នាក់ ដែលកំពុងបម្រើសេវាហិរញ្ញវត្ថុជូនដល់អតិថិជនប្រមាណជាង ១.០០០.០០០ នាក់ ក្នុងភូមិសរុបចំនួន ១៣.០០០ភូមិដែលស្មើនឹង ៩១ % ក្នុងប្រទេសកម្ពុជា។ ឥឡូវនេះ អេ អឹម ខេ ត្រូវការជ្រើសរើសបុគ្គលិកដែល មានសមត្ថភាព និងប្តេជ្ញាចិត្តខ្ពស់ចូលរួមជាមួយនឹងក្រុមការងារដ៏ច្រើនសម្បូរបែបនៅគ្រប់ការិយាល័យសាខា និងបណ្តានាយកដ្ឋានទាំងអស់ទូទាំងប្រទេស សម្រាប់បំពេញនូវតម្រូវការអាជីវកម្ម។

ចូលជាសមាជិកគ្រួសារ អេ អឹម ខេ លោកអ្នកមិនត្រឹមតែទទួលបាននូវប្រាក់បៀវត្សរ៍មួយមុខប៉ុណ្ណោះទេ អេ អឹម ខេ និងជួយ អ្នកក្នុងការអភិវឌ្ឍសមត្ថភាព និងទេពកោសល្យការងារដើម្បីឆ្ពោះទៅរកភាពរីកចម្រើននាពេលអនាគត។

**មុខដំណែង:** មន្ត្រីទំនាក់ទំនងមីក្រូឥណទាន ( ចំនួន ៤៥នាក់ )
**ទីតាំងត្រូវបំពេញការងារ:** ប្រចាំនៅតាមបណ្តាសាខាទូទាំងប្រទេស
**កាលបរិច្ឆេទឈប់ទទួលពាក្យ:** ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០២៤

## ភារៈកិច្ចនិងការទទួលខុសត្រូវ:

- សម្របសម្រួលការបង្កើតធនាគារភូមិ និងអតិថិជនឯកត្តជន
- អនុវត្តន៍ការហ្វឹកហ្វឺន និងការប្រជុំប្រចាំខែជាមួយសមាជិកធនាគារភូមិ
- ផ្សព្វផ្សាយផលិតផលរបស់ អេ អឹម ខេ ជូនទៅដល់អតិថិជនគោលដៅ
- ធ្វើការវាយតំលៃកម្ចីរបស់អតិថិជន
- ធ្វើការប្រមូលនូវការសងប្រាក់ពីអតិថិជន និងការទំលាក់ទុន
- រក្សានូវកំណត់ត្រាចលនាសាច់ប្រាក់អោយបានទៀងទាត់។

## កំរិតវប្បធម៌និងបទពិសោធន៍:

- ជានិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាប័ត្ររង, បរិញ្ញប័ត្រ ឬសញ្ញាប័ត្រដែលមានតំលៃស្មើ
- មានបទពិសោធន៍ជាមួយស្ថាប័នហិរញ្ញវត្ថុ ត្រូវបានផ្តល់អាទិភាព
- មានជំនាញទំនាក់ទំនង សម្របសម្រួល និងចេះដោះស្រាយបញ្ហា
- មានឆន្ទៈធ្វើការជាមួយសហគមន៍ជនបទ
- មានការទទួលខុសត្រូវខ្ពស់លើតួនាទី
- ត្រូវចេះអានភាសាអង់គ្លេសបន្តិចបន្តួច និងអាចប្រើប្រាស់កុំព្យូទ័របាន។

### អត្ថប្រយោជន៍ដែលបុគ្គលិកទទួលបាន

- ផ្តល់ប្រាក់បៀវត្សដោយផ្អែកលើបទពិសោធន៍ជាក់ស្តែង
- ផ្តល់ប្រាក់បៀវត្សដែលមានកំណើនទៀងទាត់ប្រចាំឆ្នាំ
- ផ្តល់ប្រាក់ឧបត្ថម្ភចូលឆ្នាំខ្មែរ ( ស្មើនឹង១០០%នៃប្រាក់បៀវត្សគោល )
- ផ្តល់ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ ( រហូតដល់៥០%នៃប្រាក់បៀវត្សគោល )
- ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់បុគ្គលិកចូលនិវត្តន៍ ( ស្មើនឹង៣០០% នៃប្រាក់បៀវត្សចុងក្រោយ )
- ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់បុគ្គលិកបម្រើការងារយូរ រហូតដល់ ២០០% នៃប្រាក់បៀវត្សគោល
- ផ្តល់ប្រាក់បំណាច់អតីតភាពការងារ និងប្រាក់បំណាច់រំលឹកអតីតភាពការងារ
- ផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដោយមិនកំណត់ ផ្អែកតាមលទ្ធផលការងារជាក់ស្តែង
- ផ្តល់ប្រាក់ឧបត្ថម្ភឯកសណ្ឋានប្រចាំឆ្នាំ
- ផ្តល់ប្រាក់ឧបត្ថម្ភថ្លៃទូរស័ព្ទប្រចាំខែ
- ផ្តល់ប្រាក់ជួលម៉ូតូ និងថ្លៃសាំងសម្រាប់បុគ្គលិកផ្នែកលក់
- ផ្តល់ការធានារ៉ាប់រងសុខភាព១០០% ដោយមិនកំណត់សម្រាប់បុគ្គលិករួមទាំងអ្នកក្នុងបន្ទុក បន្ថែមផ្តល់ថ្លៃព្យាបាលជំងឺក្រៅប្រទេសសម្រាប់បុគ្គលិក
- ផ្តល់ការធានារ៉ាប់រង២៤ម៉ោង ទៅលើគ្រោះថ្នាក់ដល់បុគ្គលិក
- ផ្តល់ប្រាក់ឧបត្ថម្ភលើការសម្រាលបុត្ររហូតដល់ ២,៤០០,០០០ រៀល
- ផ្តល់ប្រាក់កម្ចីសិក្សាក្នុងអត្រាការប្រាក់ត្រឹមតែ២%ក្នុងមួយឆ្នាំ
- ផ្តល់កម្ចីគេហដ្ឋានថ្មីដោយអត្រាការប្រាក់ត្រឹមតែ៥%ក្នុងមួយឆ្នាំ
- ផ្តល់ការឈប់សម្រាកដោយមានប្រាក់ឈ្នួលចាប់ពី១៨ថ្ងៃ ក្នុង១ឆ្នាំ
- ផ្តល់ការឈប់សម្រាកព្យាបាលជំងឺនិងការឈប់សម្រាកមាតុភាពដោយមានប្រាក់ឈ្នួលរហូតដល់ទៅ ៦ខែ
- ផ្តល់ការកសាងសមត្ថភាព និងការតម្លើងតួនាទី ដោយផ្អែកលើសមត្ថភាពនិងតម្រូវការជាក់ស្តែង។

បេក្ខជនដែលមានចំណាប់អារម្មណ៍សូមផ្ញើរប្រវត្តិរូបសង្ខេបនិងពាក្យសុំបំរើការងារ(CV and Cover Letter)មកកាន់ការិយាល័យ អេ អឹម ខេគ្រប់សាខា និង ការិយាល័យកណ្ដាល អគារលេខ២៨៥ មហាវិថី ឃោធពលខេមរភូមិន្ទ (ផ្លូវ២៧១) សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញឬតាមរយៈ E-mail: job@amkcambodia.com

**ភ្ជាប់ជាមួយៈ**

- ថតចំលងសញ្ញាប័ត្រដែលទទួលបាន ឬលិខិតបញ្ជាក់ពីសាលា / សាកលវិទ្យាល័យ
- ថតចំលងអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ និងលិខិតបញ្ជាក់កំណើត
- ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកទូរស័ព្ទលេខៈ០២៣ ៩៩៣ ០៦២/០២៣ ២២៤ ៧៦៣
  ឬវេបសាយ : www.amkcambodia.com
- អេ អឹម ខេ ផ្តល់ឱកាសស្មើៗគ្នាសំរាប់បេក្ខជនទាំងអស់។ ស្រ្តីនិងជនពិការត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យ។

*ដាក់ពាក្យនៅទីនេះ*